# សុន្ទរកថារបស់
# លោកជំទាវ គីតរ៉េត តំរង រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម
# ថ្លែងក្នុងឱកាសបើកសិក្ខាសាលា
# ស្តីពី
# "ការផ្សព្វផ្សាយកម្មវិធីអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម"
# (Trade SWAp Awareness Workshop)
# នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច,
# ថ្ងៃច័ន្ទ ទី០៤ ខែមេសា ឆ្នាំ ២០១៦

- ឯកឧត្តម..........................សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតទាំងអស់ជាទីរាប់អាន!

ថ្ងៃនេះខ្ញុំមានកិត្តិយស និងសេចក្តីរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាអធិបតីនៅក្នុងពិធីបើកសិក្ខាសាលាស្តីពី "**ការផ្សព្វផ្សាយកម្មវិធីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម**" ដ៏មានសារៈសំខាន់នេះ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំណាស់មួយនៅកម្ពុជា។ ក្នុងនាមឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិត ដែលបានអញ្ជើញមកចូលរួមសិក្ខាសាលាព្រឹកនេះយ៉ាងច្រើនកុះករ។

នាងខ្ញុំសូមជម្រាបថា អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade Sector Wide Approach) ឬ Trade SWAp គឺជាយន្តការដ៏សំខាន់របស់រាជរដ្ឋាភិបាល ដែលមានគោលបំណងលើកស្ទួយភាពជាម្ចាស់ និងពង្រឹងប្រសិទ្ធភាពជំនួយសម្រាប់ពាណិជ្ជកម្ម (Aid-for-Trade) ដែលផ្តល់តាមរយៈដៃគូអភិវឌ្ឍន៍អន្តរជាតិ ។ Trade SWAp បានចងក្រងនូវសកម្មភាពកំណែទំរង់ជាច្រើនពាក់ព័ន្ធជាមួយពាណិជ្ជកម្មទៅជាសសរស្តម្ភចំនួនបី ដើម្បីចូលរួមអភិវឌ្ឍវិស័យពាណិជ្ជកម្ម, កាត់បន្ថយ ភាពក្រីក្រ, និងជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយចេរភាព។

- <u>សសរស្តម្ភទី ១</u> ៖ កំណែទម្រង់ច្បាប់អន្តរវិស័យ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា
- <u>សសរស្តម្ភទី ២</u> ៖ ពង្រីក និងធ្វើពិពិធកម្មវិស័យនាំចេញរបស់កម្ពុជា ផ្តោតលើផលិតផលអទិភាពក្នុង CTIS
- <u>សសរស្តម្ភទី ៣</u> ៖ កសាងសមត្ថភាពរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធពាណិជ្ជកម្ម ដើម្បីដឹកនាំចរចារ និងចាត់ចែងរាល់កិច្ចការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម

ដើម្បីសម្រេចបានគោលដៅទាំងនេះ នៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងទទួលជំនួយឥតសំណងចំនួន US$15.45 លានដុល្លារ ពីម្ចាស់ជំនួយពហុភាគីមានដូចជា សហភាពអឺរ៉ុប, ភ្នាក់ងារអភិវឌ្ឍអន្តរជាតិដាណឺម៉ាក (DANIDA) និងអង្គការសហប្រជាជាតិអភិវឌ្ឍឧស្សាហកម្ម (UNIDO) ដើម្បីអនុវត្ត "**កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម**" ហៅកាត់ថា TDSP ។ កម្មវិធីនេះ មានគោលដៅបង្កើនប្រសិទ្ធភាពរាជរដ្ឋាភិបាលក្នុងការតាក់តែង និងអនុវត្តគោលនយោបាយពាណិជ្ជកម្ម និងជម្រុញការអនុវត្ត Trade SWAp ។ ទន្ទឹមគ្នានេះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) ត្រូវបានជ្រើសរើសជាភ្នាក់ងារប្រតិបត្តិ (Executing Agency) នៃកម្មវិធី TDSP និងជាលេខាធិការដ្ឋាន

របស់ Trade SWAp ហើយគម្រោងចំនួន ២៩ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ឲ្យភ្នាក់ងារអនុវត្តគម្រោងចំនួន ១៧ មកពីស្ថាប័នសាធារណៈ និងវិស័យឯកជនដែលជាប់ពាក់ព័ន្ធជាមួយវិស័យពាណិជ្ជកម្ម ដើម្បីអនុវត្ត។

កម្មវិធី TDSP ត្រូវបានអនុវត្តចំនួនជាង ៦ឆ្នាំហើយ។ ឆ្នាំ ២០១៦នេះ ជាឆ្នាំចុងក្រោយនៃការអនុវត្តកម្មវិធី ហើយបច្ចុប្បន្នគម្រោងចំនួន ២០ ត្រូវបានបញ្ចប់ នៅសល់គម្រោងចំនួន ៩ កំពុងតែដំណើរការ ហើយនឹងបញ្ចប់នៅក្នុង ខែសីហាខាងមុខនេះ។ តាមរយៈលទ្ធផលវាយតម្លៃប្រចាំរបស់ដៃគូអភិវឌ្ឍអន្តរជាតិ បានទទួលស្គាល់ថា ការអនុវត្តគម្រោង TDSP ទទួលបានលទ្ធផលគួរជាទីពេញចិត្ត (Satisfactory Level) ចំនួន ៣ ឆ្នាំជាប់ៗគ្នា ហើយគឺជាគម្រោងដែលល្អបំផុត នៅក្នុងចំណោមគម្រោងទាំងអស់ដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។

តាមរយៈការអនុវត្តកម្មវិធី TDSP បានធ្វើឲ្យរាជរដ្ឋាភិបាល មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ និងតាក់តែងនូវគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា សំដៅធ្វើសមាហរណកម្មវិស័យពាណិជ្ជកម្ម ចូលទៅក្នុងបណ្តាញផលិតកម្មនៃប្រទេសនៅក្នុងតំបន់ និងលើពិភពលោក។ ការដាក់ចេញនូវកំណែទម្រង់ថ្មីៗរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីជួយអភិវឌ្ឍន៍វិស័យឯកជន ឲ្យក្លាយទៅជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិនាពេលកន្លងមក គឺជាឧទាហរណ៍មួយដែលបង្ហាញប្រសិទ្ធភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។ តាមរយៈកំណែទម្រង់នេះ បានធ្វើឲ្យចំណាត់ថ្នាក់នៃភាពងាយស្រួលក្នុងការធ្វើធុរកិច្ចរបស់កម្ពុជា កើនឡើងចំនួន ៦ខ្ទង់បើប្រៀបធៀបនឹងឆ្នាំ ២០១៤ ពោលគឺបានថយចុះពីលេខរៀងទី ១៣៣ មកនៅត្រឹមលេខ ១២៧ សម្រាប់ឆ្នាំ ២០១៥។ លើសពីនេះចំណាត់ថ្នាក់ស្តីពីសន្ទស្សន៍ប្រតិបត្តិការដឹកជញ្ជូន (Logistic Performance Index) របស់កម្ពុជា ក៏បានថយចុះពីលេខ ១២៣ នៅក្នុងឆ្នាំ ២០១០ មកនៅត្រឹមលេខ ៨៣ ក្នុងឆ្នាំ ២០១៤ ផងដែរ នេះបើតាមរបាយការណ៍របស់ធនាគារពិភពលោក។

**លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតទាំងអស់ជាទីមេត្រី!**

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់ ដែលបានចូលរួមផ្តល់ជំនួយហិរញ្ញប្បទានដល់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្មនាពេលកន្លងមក ហើយក៏សូមអគុណជាអនេកប្បការដល់មន្ត្រីរាជការ និងជំនាញការទាំងអស់ ដែលបានខិតខំបំពេញការងារយ៉ាងយកចិត្តទុកដាក់ ប្រកបដោយស្មារតីទទួលខុសត្រូវ ដើម្បីសម្រេចបាននូវវត្ថុបំណងរបស់កម្មវិធី ព្រមទាំងសមិទ្ធផលសំខាន់ៗសម្រាប់វិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ចជាតិ ដែលបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជាចំនួន ១% រៀងរាល់ឆ្នាំ។

អាស្រ័យហេតុនេះ ដើម្បីស្វែងយល់ថាតើរាជរដ្ឋាភិបាលបានប្រឹងប្រែងអភិវឌ្ឍវិស័យពាណិជ្ជកម្មយ៉ាងដូចម្តេច និងតើកម្មវិធី TDSP មានសកម្មភាព និងមានអត្ថប្រយោជន៍បែបណាចំពោះវិស័យពាណិជ្ជកម្ម ក៏ដូចជាវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា? ខ្ញុំសូមឲ្យលោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតដែលមានវត្តមាននៅទីនេះ មេត្តាយកចិត្តទុកដាក់ចូលរួមស្តាប់ និងលើកឡើងរាល់ចម្ងល់នានា ដែលទាក់ទងកម្មវិធី TDSP និង Trade SWAp ដើម្បីជាបច្ច័យទទួលបានពុទ្ធិថ្មីៗបន្ថែមសម្រាប់អភិវឌ្ឍខ្លួនឯង និងកសាងប្រទេសយើងឲ្យកាន់តែរីកចម្រើន ដូចប្រទេសជឿនលឿននានាក្នុងពិភពលោក។

នៅពេលនេះ ខ្ញុំសូមប្រកាសបើកសិក្ខាសាលាជាផ្លូវការ និងសូមជូនពរដល់លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតទាំងអស់ ទទួលបានផ្លែផ្កាប្រកបដោយជោគជ័យពីសិក្ខាសាលាថ្ងៃនេះ ។ សូមអគុណ!